HR & TRAINING SOLUTION
Your Great Partner

គ្រូបង្វឹក ៥ ប្រភេទ ដែលអ្នកគួរតែដឹង



ការបង្វឹក គឺជាការផ្តល់នូវមតិយោបល់ដល់នរណាម្នាក់ អំពីរបៀប ដើម្បីឈានទៅរកភាពជោគជ័យផ្ទាល់ខ្លួនក្នុងតួនាទី ឬ កិច្ចការរបស់ពួកគេ។ មនុស្សដែលជោគជ័យក្នុងជីវិតដោយសារតែមានមនុស្សល្អៗ នៅក្បែរខ្លួនចាំណែនាំផ្លូវគ្រប់ពេលវេលា។ បើយើងក្រឡេកមើលទៅបណ្តា កីឡាករ កីឡាការិនីជម្រើសជាតិ បណ្តាអ្នកជំនួញ អ្នកវិនិយោគ ក្រុមគ្រួសារដែលមានសុភមង្គល អ្នកហាត់ប្រាណដែលមានរូបរាងស្រស់សង្ហា ពួកគាត់សុទ្ធតែមានគ្រូបង្វឹកយ៉ាងតិចម្នាក់ចាំជួយបង្ហាត់បង្ហាញពួកគាត់ជាប្រចាំ។ ជាកាតព្វកិច្ចរបស់មនុស្សទូទៅ ដើម្បីកំណត់ថាតើគ្រូបង្វឹកណាមួយសមនឹងតម្រូវការគោលដៅ និងរបៀបរស់នៅរបស់យើងបាន ហើយក៏ដើម្បីជួយយើងក្នុងការកំណត់នូវអ្វីដែលយើងត្រូវការ។ នេះគឺជាគ្រូបង្វឹក ៥ ប្រភេទដែលយើងគួរតែដឹង៖



គ្រូបង្វឹកអាជីព

គ្រូបង្វឹកប្រភេទនេះ គឺល្អសម្រាប់អ្នកគ្រប់គ្រង និងអ្នកដឹកនាំដទៃទៀត នៅក្នុងពិភពជំនួញដែលចង់ចាប់យកជំនាញរបស់ពួកគេទៅកម្រិតបន្ទាប់។ មានភាពខុសគ្នារវាងបុគ្គលិកល្អ អ្នកគ្រប់គ្រងល្អ និងចៅកែគួរឲ្យខ្លាច។ ឧទាហរណ៍ បុគ្គលិកល្អ គឺជាអ្នកដែលបំពេញភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ ប៉ុន្តែពួកគេមិនអាចធ្វើការសម្រេចចិត្តសំខាន់ៗដោយខ្លួនឯងបានទេ ហើយខ្វះជំនាញដែលត្រូវការ ដើម្បីត្រួតពិនិត្យក្រុមអ្នកក្រោមបង្គាប់។ ចៅហ្វាយគួរឲ្យខ្លាច គឺជាមនុស្សដែលមិនអាចទទួលយកកំហុសរបស់ពួកគេ ហើយធ្វើឲ្យបុគ្គលិកមិនសប្បាយចិត្ត។

បើប្រៀបធៀបអ្នកគ្រប់គ្រងល្អ គឺជាអ្នកដឹកនាំអ្នកក្រោមបង្គាប់ប្រកបដោយប្រសិទ្ធភាព ហើយអាចបង្កើនជំនាញរបស់ពួកគេនៅក្នុងឧស្សាហកម្មនេះ។ ហើយគ្រូបង្វឹកដឹកនាំអាជីវកម្ម គឺជាអ្នកដែលមានជំនាញក្នុងការបង្កើតអ្នកដឹកនាំអាជីវកម្មនៅថ្ងៃខាងមុខ។



HR & TRAINING SOLUTION
Your Great Partner

គ្រូបង្វឹកដឹកនាំអាជីវកម្ម

គ្រូបង្វឹកប្រភេទនេះ គឺល្អសម្រាប់អ្នកគ្រប់គ្រង និងអ្នកដឹកនាំដទៃទៀត នៅក្នុងពិភពជំនួញដែលចង់ចាប់យកជំនាញរបស់ពួកគេទៅកម្រិតបន្ទាប់។ មានភាពខុសគ្នារវាងបុគ្គលិកល្អ អ្នកគ្រប់គ្រងល្អ និងចៅកែគួរឲ្យខ្លាច។ ឧទាហរណ៍ បុគ្គលិកល្អ គឺជាអ្នកដែលបំពេញភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ ប៉ុន្តែពួកគេមិនអាចធ្វើការសម្រេចចិត្តសំខាន់ៗដោយខ្លួនឯងបានទេ ហើយខ្វះជំនាញដែលត្រូវការ ដើម្បីត្រួតពិនិត្យក្រុមអ្នកក្រោមបង្គាប់។ ចៅហ្វាយគួរឲ្យខ្លាច គឺជាមនុស្សដែលមិនអាចទទួលយកកំហុសរបស់ពួកគេ ហើយធ្វើឲ្យបុគ្គលិកមិនសប្បាយចិត្ត។

បើប្រៀបធៀបអ្នកគ្រប់គ្រងល្អ គឺជាអ្នកដឹកនាំអ្នកក្រោមបង្គាប់ប្រកបដោយប្រសិទ្ធភាព ហើយអាចបង្កើនជំនាញរបស់ពួកគេនៅក្នុងឧស្សាហកម្មនេះ។ ហើយគ្រូបង្វឹកដឹកនាំអាជីវកម្ម គឺជាអ្នកដែលមានជំនាញក្នុងការបង្កើតអ្នកដឹកនាំអាជីវកម្មនៅថ្ងៃខាងមុខ។



HR & TRAINING SOLUTION
Your Great Partner

គ្រូបង្វឹកជីវិតហិរញ្ញវត្ថុ

មនុស្សជាច្រើនសុបិនចង់រស់នៅដោយគ្មានបំណុលនាពេលអនាគត ដែលពួកគេរស់នៅក្នុងផ្ទះដ៏ស្រស់ស្អាត ជាមួយមនុស្សជាទីស្រឡាញ់។ គ្រូបង្វឹកជីវិតហិរញ្ញវត្ថុ គឺជាអ្នកជំនាញដែលផ្តល់ជូនអតិថិជននូវដំណោះស្រាយហិរញ្ញវត្ថុ រួមទាំងឲ្យយើងទទួលបានសេរីភាពហិរញ្ញវត្ថុនៅអាយុដំបូងដែលអាចធ្វើទៅបាន។



ដូចគ្នានេះផងដែរ គ្រូបង្វឹកជីវិតហិរញ្ញវត្ថុ អាចជួយយើងកាត់បន្ថយចំណាយដែលមិនចាំបាច់ ដូច្នេះយើងអាចសន្សំសំចៃសម្រាប់អ្វីដែលសំខាន់ជាងបានច្រើន។

HR & TRAINING SOLUTION
Your Great Partner

គ្រូបង្វឹកសុខភាព



អ្នកបង្ហាត់ហាត់ប្រាណ អាចធ្វើបានច្រើន ដើម្បីជួយយើងឲ្យសម្រេចបានក្តីសុបិនដែលយើងចង់បាន។ ពួកគេធ្វើការរួមគ្នាជាមួយយើង ដើម្បីបង្កើតរបបអាហារហាត់ប្រាណដែលមានសុខភាពល្អ និងគោលដៅនៃរាងកាយតាមភាពជាក់ស្តែង។ ជាញឹកញាប់ គ្រូបង្វឹកសុខភាព នឹងជំរុញយើងឲ្យរក្សាភាពស្មោះត្រង់ចំពោះការហាត់ប្រាណ និងរបបអាហារ ដោយរំឭកយើងជានិច្ចពីគោលដៅថ្ងៃខាងមុខ។

គ្រូបង្វឹកជីវិតក្រោយលះលែង

ការលែងលះ គឺជាហេតុការណ៍រំជួលចិត្ត និងសោកនាដកម្មមួយគួរឲ្យស្តាយ ដែលទាក់ទងនឹងការងារច្បាប់ស្មុគស្មាញជាច្រើន។ ការថែរក្សាហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ជារឿងមួយចំនួនដែលគូស្វាមីភរិយាដែលបែកបាក់គ្នា ត្រូវដោះស្រាយ។ ហើយគូស្វាមីភរិយាភាគច្រើន សម្រេចបានលទ្ធផលតិចតួចក្នុងកំឡុងពេលដំណើរការ ពីព្រោះភារកិច្ចទាំងនេះ មានទំនោរនាំមកនូវការចងចាំមិនល្អ។
ប៉ុន្តែ គ្រូបង្វឹកជីវិត មានជំនាញក្នុងការប្រឹក្សាប្តីប្រពន្ធដែលចង់លែងលះ។ ការដែលមានភាគីទីបីជួយ ធ្វើឱ្យដំណើរការកាន់តែលឿន និងងាយស្រួល ថែមទាំងផ្តល់នៅគោលបំណងនៃទស្សនៈ និងជួយឲ្យគូស្វាមីភរិយាបោសសម្អាតបញ្ហាជាច្រើនថែមទៀតផង។



HR & TRAINING SOLUTION
Your Great Partner

The HRDaily

បណ្ណាល័យអ្នក - Banalai Neak

HRTS CONSULTING

www.thehrdaily.com